**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**
**អគ្គលេខាធិការដ្ឋាន**
លេខ: ០៥២/ ១៥ របក អ.ជ.ប.គ.ញ

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០១៥

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែឧសភា ឆ្នាំ២០១៥ និងទិសដៅការងារ ខែមិថុនា ឆ្នាំ២០១៥
(ពីថ្ងៃទី ២៦/៤/២០១៥ - ២៥/៥/២០១៥)

ក្នុងគោលដៅចូលរួមចំណែកអនុវត្ត " គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព " របស់រាជរដ្ឋាភិបាល ក៏ដូចជាអនុវត្តតាមផែនការសកម្មភាពនៃទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ដែលបានដាក់ចេញកាលពីខែមេសា ឆ្នាំ២០១៥ កន្លងទៅ សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម ៖

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

នៅក្នុងខែឧសភាឆ្នាំ២០១៥នេះ ការបង្ក្រាបបទល្មើសគ្រឿងញៀនត្រូវបានបើកកិច្ចប្រតិបត្តិការ ដោយមន្ទីរប្រឆាំងគ្រឿងញៀន និងបណ្តាស្នងការដ្ឋាននគរបាល បញ្ជាការដ្ឋានកងរាជអាវុធហត្ថ រាជធានី ខេត្ត ទាំង ២៥ នៅទូទាំងប្រទេស ។

ក្រៅពីការងារបង្ក្រាបបទល្មើសគ្រឿងញៀននៅក្នុងប្រទេស តាមរយៈការិយាល័យទំនាក់ទំនងព្រំដែន (BLO) ត្រពាំងគ្រៀល ខេត្តស្ទឹងត្រែង បានផ្តល់ព័ត៌មានទៅការិយាល័យ BLO កាតីឡាវ ចំនួនពីរលើក និងឈានទៅបង្ក្រាបបានពីរករណីដោយសមត្ថកិច្ចឡាវ នៅចំណុចភូមិឃីណាក ស្រុកខុង ខេត្តចំប៉ាសាក់ ដោយចាប់ខ្លួនជនសង្ស័យចំនួន ៤ នាក់ ក្នុងនោះជាជនជាតិឡាវ ៣ នាក់ និងជនជាតិខ្មែរ ១ នាក់ ព្រមទាំងចាប់យក មេតំហ្វេតាមីន WY ៣.២០០ គ្រាប់ និង មេតំហ្វេតាមីនក្រាមម្សៅ ICE ចំនួន ៦ គីឡូក្រាម ។

## II. អំពីការងារដឹកនាំ

### ១. ការងារដឹកនាំរបស់ស្ថាប័នកំពូលថ្នាក់ជាតិ

រាជរដ្ឋាភិបាល ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចេញសារាចរលេខ ០៣ សរ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការចាត់តាំងខួបលើកទី៦៦ ទិវាកុមារអន្តរជាតិ ១មិថុនា ខួបលើកទី១៤ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៥ ដើម្បីតម្រូវឱ្យរួមគ្នាដោះស្រាយឱ្យបានទាន់ពេលវេលានិងចំគោលដៅ ចំពោះកុមារកម្ពុជាដែលនៅប្រឈមមុខជាមួយនឹងបញ្ហាមួយចំនួននៅឡើយ ដូចជា អំពើហឹង្សាលើកុមារ ការប្រើប្រាស់គ្រឿងញៀន អនីតិជនទំនាស់នឹង



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529
E-mail: info@nacd.gov.kh, Website : www.nacd.gov.kh

ច្បាប់ អំពើជួញដូរកុមារ ពលកម្មកុមារ កុមារខ្វះអាហារូបត្ថម្ភ កុមារបោះបង់ចោលការសិក្សា កុមារចំណាកស្រុក ។ល។

## ២. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តដឹកនាំ និងណែនាំលើការងារជាគោលសំខាន់ៗ មានដូចជា ៖

- ណែនាំឱ្យក្រុមប្រតិភូរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ទៅចូលរួមប្រារព្ធទិវាកុមារអន្តរជាតិលើកទី ៦៦ នៅវិទ្យាល័យឥន្រ្ទទេវី (ថ្ងៃទី៣០/៥/២០១៥)
- បន្តជំរុញក្រសួងអប់រំ យុវជន និងកីឡា ក្នុងការរៀបចំសាលារៀនបៃតង (សាលារៀនគ្មានគ្រឿងញៀន)
- បន្តរៀបចំផលិតឯកសារផ្សព្វផ្សាយអប់រំ ពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន
- បន្តពង្រឹងសមត្ថភាព និងកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប និងព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- បន្តពង្រីកកម្មវិធីព្យាបាលដោយផ្អែកលើសហគមន៍ ដោយរៀបចំយន្តការដាក់លាក់តាមខ្លឹមសារបីគឺ ការព្យាបាល ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការធ្វើសមាហរណកម្ម
- បន្តការរៀបចំស្លាកសញ្ញា ដើម្បីដាក់បង្ហាញនៅតាមមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព ដែលបានរៀបចំរួចក្នុងរាជធានីភ្នំពេញ និងបន្តជំរុញកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍នៅ រាជធានីភ្នំពេញឱ្យកាន់តែមានសកម្មភាពផុលផុស
- បន្តធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយពីកម្មវិធីផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀន នៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព និងកម្មវិធីម្តុល/ស៊ីប៉ាំងនៅកម្ពុជា
- បន្តធ្វើសម្រង់បទល្មើសនានា ដែលកើតឡើងដោយសារការប្រើប្រាស់គ្រឿងញៀន និងបទល្មើសគ្រឿងញៀន ដោយបញ្ជាក់ពីមុខរបរជនល្មើសឱ្យបានច្បាស់លាស់ សម្រាប់ឆមាសទី១ ឆ្នាំ២០១៥
- បន្តធ្វើសម្រង់បទល្មើសគ្រឿងញៀនក្នុងដែនសមត្ថកិច្ចតុលាការ
- ជំរុញអនុវត្តខ្លឹមសារដែលបានឯកភាពគ្នាជាមួយភាគីឡាវ (ក្នុងដំណើរទស្សនកិច្ចផ្លូវការ កាលពីថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១៥) ដូចខាងក្រោម ៖
    - ជំរុញកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងជនសង្ស័យជួញដូរគ្រឿងញៀន និងពង្រឹងកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនតាមតំបន់ព្រំដែនកម្ពុជា ឡាវ
    - ពង្រឹងគណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀន នៅខេត្តជាប់ព្រំដែនកម្ពុជា ឡាវ
    - ធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំមន្ត្រីទំនាក់ទំនងព្រំដែនលើបញ្ហាគ្រឿងញៀនកម្ពុជា ឡាវ លើកទី១
    - សហការជាមួយភាគីឡាវ ដើម្បីរៀបចំឯកសារអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន ជាភាសាកម្ពុជា ឡាវ សម្រាប់ប្រជាជនដែលរស់នៅតាមតំបន់ព្រំដែន
    - រួមគ្នាបង្កើតភូមិ សាលារៀននៅតាមតំបន់ព្រំដែន គ្មានគ្រឿងញៀន
- បន្តរៀបចំព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បន្តជំរុញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ឱ្យអនុវត្តផែនការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ ២០១៥ ពិសេសដំណើរការព្យាបាលដោយផ្អែកលើសហគមន៍ ដោយពង្រឹងយន្តការគ្រប់គ្រងលើការព្យាបាល បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្ម ។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

ក្នុងខែឧសភាឆ្នាំ២០១៥នេះ ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈពីផលប៉ះពាល់និងគ្រោះថ្នាក់ នៃគ្រឿងញៀន ក្រសួងជាសមាជិករបស់អាជ្ញាធរជាតិ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿញៀនរាជធានី ខេត្តនៅទូទាំងប្រទេសបានបន្តអនុវត្តការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ តាមរយៈស្ថានីយវិទ្យុជាតិ វិទ្យុរាជធានី ខេត្តរបស់ខ្លួន ។

ដោយឡែក ការអប់រំតាមសហគមន៍ ក្រៅពីការអនុវត្តដោយក្រសួង ស្ថាប័នជាសមាជិក អ.ជ.ប.គ.៣ ក៏នៅមានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន ១១ គឺ ខេត្តក្រចេះ ស្វាយរៀង កំពង់ឆ្នាំង កណ្តាល កំពង់ស្ពឺ ពោធិ៍សាត់ ប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ចាម ដែលបានចូលរួមអនុវត្តសកម្មភាពខាងលើ ដែលលទ្ធផលជារួម មានមហាជនចូលរួមប្រមាណ **៨៣១.៧០៥** នាក់ លើ ១.០៤៤.៣៧៥ នាក់ នៃខែមេសា ឆ្នាំ២០១៥ ដូចមានក្នុងតារាងឧបសម្ព័ន្ធទី១ ។

ក្នុងចំណោមសកម្មភាពខាងលើ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ បានចូលរួមអនុវត្តដូចតទៅ ៖

- រៀបចំនិងអញ្ជើញវាគ្មិនជាតំណាងមកពីធនាគារជាតិនៃកម្ពុជា, ក្រសួងឧស្សាហកម្មនិងសិប្បកម្ម, ក្រសួងកិច្ចការនារី ដើម្បីផ្តល់កិច្ចសម្ភាសន៍ក្នុង ៖
  - កម្មវិធីព័ត៌មានពេលថ្ងៃ របស់ស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី ក្រោមប្រធានបទស្តីពី ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនតាមប្រព័ន្ធធនាគារ នៅកម្ពុជា (២៧.៥.២០១៥)
  - កម្មវិធីសភាអ៊ីនធឺណែត របស់ស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី ក្រោមប្រធានបទស្តីពី ការអប់រំផ្សព្វផ្សាយដើម្បីបង្ការបញ្ហាគ្រឿងញៀនក្នុងវិស័យកិច្ចការនារី នៅកម្ពុជា (២៧.៥.២០១៥)
- ជួបពិភាក្សាការងារជាមួយក្រសួងទេសចរណ៍ ដើម្បីបង្កើនសកម្មភាពអប់រំពីបញ្ហាគ្រឿងញៀនក្នុងវិស័យទេសចរណ៍ និងរៀបចំផែនការ យន្តការឱ្យបានច្បាស់លាស់សម្រាប់អនុវត្តសកម្មភាពនេះ កាលពីថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៥
- សហការជាមួយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចុះផ្សព្វផ្សាយអប់រំពីច្បាប់ ផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀននៅខេត្តកំពង់ស្ពឺ មានអ្នកចូលរួម ៤៧៥ នាក់
- សម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបញ្ជូនសិស្សវិទ្យាល័យចំនួន ៤ នាក់ និងមន្ត្រីអគ្គលេខាធិការដ្ឋាន ១ នាក់ (ជាអ្នកដឹកនាំសិស្ស) ទៅចូលរួមសិក្ខាសាលាបណ្តុះបណ្តាលសម្រាប់យុវជនអាស៊ានស្តីពីការអភិវឌ្ឍសង្គម និងការបង្ការការប្រើបំពានគ្រឿងញៀនឆ្នាំ២០១៥ ដែលរៀបចំនៅប្រទេសថៃ កាលពីថ្ងៃទី២៤-៣១ ខែឧសភា ឆ្នាំ ២០១៥
- ផ្តល់បទឧទ្ទេសនាមដល់សិស្សថ្នាក់ទី១១ នៃសាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ ចំនួន ១.៣២១ នាក់ ក្រោមប្រធានបទស្តីពីការយល់ដឹងទូទៅពីគ្រឿងញៀន កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៥
- បាននិងកំពុងបន្តកិច្ចសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា ក្រសួងមហាផ្ទៃ ដើម្បីរៀបចំវគ្គផ្សព្វផ្សាយចំណេះដឹងជាមូលដ្ឋានពីបញ្ហាគ្រឿងញៀន
- សហការជាមួយក្រុមហ៊ុន ហ្វូមមេឌា បញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀននៅខេត្តបាត់ដំបង តាមរយៈកម្មវិធីប្រគំតន្ត្រីតាំងពិព័រណ៍ផលិតផលកម្ពុជា ថៃ (២២/៥/២០១៥) អ្នកចូលរួម ៣០.០០០ នាក់
- រៀបចំបោះពុម្ពស្ទីកឃ័រ (Sticker) សម្រាប់ចែកផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន នៅតាមមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍គោលដៅសំខាន់ៗ និងនៅតាមច្រកទ្វារព្រំដែនអន្តរជាតិ
- គាំទ្រសកម្មភាពរបស់អង្គការ កិច្ចសហការដើម្បីកម្ពុជា (អង្គការកាកូ) ដែលបានធ្វើសកម្មភាពបណ្តុះ

បណ្ដាលដល់ក្រុមជនបង្គោល និងអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀននៅខេត្តពោធិ៍សាត់ ប៉ៃលិន បន្ទាយមានជ័យ បាត់ដំបង និងខេត្តសៀមរាប ទទួលបានលទ្ធផលដូចខាងក្រោម ៖

- អប់រំផ្សព្វផ្សាយដល់ក្រុមគោលដៅងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់ សរុបចំនួន ២២៧ នាក់
- បណ្ដុះបណ្ដាលក្រុមជនបង្គោលជាមេឃុំ ចៅសង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រធានភូមិ និងកិច្ចការនារីភូមិ សរុបចំនួន ៦៩ នាក់

• តាមរយៈគេហទំព័ររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (www.nacd.gov.kh) ក្នុងខែឧសភា ឆ្នាំ២០១៥ មានអ្នកអានចំនួន **២៥.២១៦** ដង លើ ៤១.២៨៦ ដង នៃខែមេសា ឆ្នាំ២០១៥ ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ ចំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់

- សហការជាមួយក្រសួងសុខាភិបាល និងអង្គការ FHI360 រៀបចំកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការសិក្សាស្រាវជ្រាវពីការអនុវត្តកម្មវិធីបង្ការមេរោគអេដស៍ និងគ្រឿងញៀននៅកម្ពុជា (CIPI) នៅ ៖
  - ខេត្តព្រះសីហនុ ថ្ងៃទី១៩ខែឧសភាឆ្នាំ២០១៥ មានមន្ត្រីពាក់ព័ន្ធចូលរួម **៦០** នាក់
  - ខេត្តកំពង់ថ្លាំង ថ្ងៃទី២១ខែឧសភាឆ្នាំ២០១៥ មានមន្ត្រីពាក់ព័ន្ធចូលរួម **៦០** នាក់
- បាននិងកំពុងពិនិត្យ ផ្តល់យោបល់លើសេចក្តីព្រាងផែនការសកម្មភាព សម្រាប់កិច្ចសហប្រតិបត្តិការរវាងប្រទេសជាសមាជិករបស់ Conference on Interaction and Confidence Building Measure in Asia (CICA)
- អនុញ្ញាតឱ្យអង្គការ កសាង បន្តអនុវត្តកម្មវិធី ម្តុល / ស៊ីរ៉ាំង រយៈពេល១ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៥ ដល់ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៦

### ២.២. ការព្យាបាល ស្តារនីតិសម្បទា

- ចូលរួមសន្និសីទអាស៊ានលើកទី១ (ដោយក្រសួងសុខាភិបាល) ស្តីពីការសិក្សាស្រាវជ្រាវ និងព្យាបាលអ្នកញៀនគ្រឿងញៀន ដែលបានរៀបចំនៅប្រទេសថៃ កាលពីថ្ងៃទី០៥-០៨ ខែឧសភា ឆ្នាំ២០១៥
- បានចូលរួមវគ្គបណ្តុះបណ្តាលជាលក្ខណៈអន្តរជាតិស្តីពីការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលបានរៀបចំនៅប្រទេសថៃ កាលពីថ្ងៃទី១៨-២៩ ខែឧសភា ឆ្នាំ២០១៥ (មន្ត្រីអគ្គលេខាធិការដ្ឋាន ១ នាក់, មន្ត្រីក្រសួងសុខាភិបាល ១ នាក់, មន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ១ នាក់)

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

### ៣.១. ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់

- បានបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីនៃកងយោធពលខេមរភូមិន្ទ ពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ការបង្ការ ទប់ស្កាត់ការប្រើប្រាស់ និងការជួញដូរគ្រឿងញៀន នៅសាលានាយទាហានសកម្មត្នោតពង ចំនួន ២៦៥ នាក់ (២៧/៤/២០១៥), វិទ្យាស្ថានកងទ័ពជើងគោកថ្កុកតាសេក ចំនួន ១.០៤០ នាក់ (២៨/៤/២០១៥) និងនៅមជ្ឈមណ្ឌលកងទ័ពជើងគោកពេជ្រនិល ចំនួន ១២០ នាក់ (២៩/៤/២០១៥) **សរុប ១.៤២៥ នាក់**
- បើកវគ្គបណ្តុះបណ្តាលមន្ត្រីកងរាជអាវុធហត្ថរាជធានីភ្នំពេញ ១២ នាក់ (វគ្គ២/ឆ្នាំ២០១៥) កាលពីថ្ងៃទី១៨-២២/ ៥/២០១៥ ស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមប្រព័ន្ធកុំព្យូទ័រ (CBT)

- ចូលរួមវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់អន្តរជាតិ នៅទីក្រុងបាងកក ប្រទេសថៃ កាលពីថ្ងៃទី២៧ ខែមេសា ដល់ ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥ (មន្ត្រីអគ្គលេខាធិការដ្ឋាន ១ នាក់)
- ចូលរួមវគ្គបណ្តុះបណ្តាលអនុវត្តច្បាប់គ្រឿងញៀនអាស៊ាន + ៣ លើកទី២ ស្តីពីការប្រឆាំងថ្នាំញៀន ATS និងសារធាតុញៀនផ្សេងទៀត ដែលបានរៀបចំនៅប្រទេសថៃ កាលពីថ្ងៃទី១១-១២ ខែឧសភា ឆ្នាំ២០១៥ (មន្ត្រីអគ្គលេខាធិការដ្ឋាន ១ នាក់, មន្ត្រីគយ រដ្ឋាករ ១ នាក់ និងមន្ត្រីនគរបាលខេត្តបន្ទាយមានជ័យ ១ នាក់)
- ចូលរួមកិច្ចប្រជុំស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមអាកាសយានដ្ឋានអន្តរជាតិ នៃបណ្តាប្រទេសអាស៊ាន លើកទី៥ ដែលបានរៀបចំនៅប្រទេសសឹង្ហបុរី កាលពីថ្ងៃទី១៣-១៤ ខែឧសភា ឆ្នាំ២០១៥ (មន្ត្រីអគ្គលេខាធិការដ្ឋាន ១ នាក់ និងគយនិងរដ្ឋាករ ១ នាក់)
- ចូលរួមហ្វឹកហ្វឺនស្តីពីនីតិវិធីពហុប្រតិបត្តិការប្រចាំតំបន់ (SOPMOC) កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០១៥ នៅទីក្រុងបាងកក ប្រទេសថៃ
- បាននិងកំពុងពិនិត្យលើសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នាស្តីពី ការប្រយុទ្ធប្រឆាំងសារធាតុថ្មីដែលប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ រវាងកម្ពុជា-រុស្ស៊ី
- បាននិងកំពុងពិនិត្យលើអនុសាសន៍នៃកិច្ចសហប្រតិបត្តិការជួយគ្នាទៅវិញទៅមក ស្តីពីវិធីសាស្រ្តនៃការប្រគល់ដោយមានការឃ្លាំមើល រវាងសហព័ន្ធសេវានៃរុស្ស៊ីក្នុងការត្រួតពិនិត្យការចរាចរគ្រឿងញៀន ជាមួយនឹងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

## ៣.២. ការបង្រ្កាបបទល្មើសគ្រឿងញៀន

- បទល្មើសគ្រឿងញៀន សរុប **២៦១** ករណី លើ ២២៥ ករណី នៃខែមេសា ឆ្នាំ២០១៥
- ជនសង្ស័យឃាត់ខ្លួន សរុប ៥៥៩ នាក់ (ស្រី ៦៧ នាក់) លើ ៤៨០ នាក់ នៃខែមេសា ឆ្នាំ២០១៥ ក្នុងបទល្មើសគ្រឿងញៀន ២៦១ ករណី និងជនសង្ស័យ ៥៥៩ នាក់ ខាងលើគឺ ៖
    - បទល្មើសគ្រឿងញៀនបង្រ្កាបដោយ សមត្ថកិច្ចនគរបាលជាតិ **២០៨** ករណី, ជនសង្ស័យ **៣៩៣** នាក់ (ស្រី ៣៩ នាក់)
    - បទល្មើសគ្រឿងញៀនបង្រ្កាបដោយ សមត្ថកិច្ចកងរាជអាវុធហត្ថ **៥៣** ករណី, ជនសង្ស័យ **១៦៦** នាក់ (ស្រី ២៨ នាក់)
- ក្នុងចំនួនជនសង្ស័យ ៥៥៩ នាក់ ខាងលើមាន ៣ សញ្ជាតិគឺ ខ្មែរ ៥៥៣ នាក់ (ស្រី ៦៥ នាក់), វៀតណាម ៥ នាក់ (ស្រី ២ នាក់), នីហ្សេរីយ៉ា ១ នាក់ (ប្រុស) ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត
- វត្ថុតាងគ្រឿងញៀនចាប់យក មេតំហ្វេតាមីន (WY) ១០៥,៩៧ ក្រាម មេតំហ្វេតាមីនក្រាមម្សៅ (ICE) ១.៦៨៨,៦៧ ក្រាម ដើមកញ្ឆា ៨២៦០ ដើម កញ្ឆាក្រៀម ៦ គ.ក្រ ១៤៧ ក្រាម ៥០
- ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនដែលបានចាប់យក ៖ ម៉ូតូ ១៣៤ គ្រឿង រថយន្ត ៣ គ្រឿង ប្រាក់កម្ពុជា ៨.៩៥៤.២០០ រៀល ប្រាក់ថៃ ៣.៧៨០ បាត ប្រាក់អាមេរិក ១០១.២៣៦ ដុល្លារ (ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២)
- ជនសង្ស័យចាប់តាមដីកា មាន ១៥ ដីកា = មនុស្ស ១៥ នាក់ (ប្រុស) ជនជាតិខ្មែរ
- សំណាកសង្ស័យជាគ្រឿងញៀន ដែលបានធ្វើកោសល្យវិច័យក្នុងខែឧសភា ឆ្នាំ២០១៥ សរុប ១១៨ សំណាក = ១០៩ ករណី ក្នុងនោះ ៖

- សំណាកវិជ្ជមានសារធាតុញៀន មាន ១១១ សំណាក = ១០៥ករណីគឺ
  - មេតំហ្វេតាមីន ICE ៩៥ សំណាក = ៨០,៥០ %
  - មេតំហ្វេតាមីន WY ១២ សំណាក = ១០,១៦ %
  - ហេរ៉ូអ៊ីន ០១ សំណាក = ០,៨៤ %
  - កេតាមីន ០២ សំណាក = ១,៦៩ %
  - MDMA ០១ សំណាក = ០,៨៤ %
- សំណាកអវិជ្ជមានសារធាតុញៀន ០៧ សំណាក = ០៤ ករណី

- បាននិងកំពុងធ្វើការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមហ៊ុន MEDICOM Co., Ltd ដើម្បីនាំចូលនូវម៉ាស៊ីនវិភាគគ្រឿងញៀន ១ គ្រឿង សម្រាប់មន្ទីរពិសោធន៍គ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

- បានដកស្រង់ទិន្នន័យសារធាតុគីមីផ្សំ ដែលពាក់ព័ន្ធនឹងតារាង IV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន សរុបមានចំនួន **១៥៩.៣៣០** គ.ក្រ ក្នុងនោះ សារធាតុគីមីផ្សំពាក់ព័ន្ធនឹងតារាង IV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលមាន ៖
  - បទដ្ឋានបច្ចេកទេសឱ្យនាំចូលដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម មាន ១២២.០០០ គ.ក្រ
  - អាជ្ញាប័ណ្ណឱ្យនាំចូលដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មាន ៣៧.៣៣០ គ.ក្រ
- បានជួបពិភាក្សាលើការងារប្រមូលទិន្នន័យ និងព័ត៌មានពីសារធាតុគីមី ដែលបាននិងកំពុងធ្វើចរាចរ នាំចេញ នាំចូល ផលិត ស្តុកទុក ដឹកជញ្ជូន ចែកចាយ និងប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា ជាមួយក្រុមហ៊ុន JWD ASIA Co., Ltd កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥ ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

- ទំនាក់ទំនងជាមួយស្ថានទូតថៃប្រចាំនៅកម្ពុជា ដើម្បីរៀបចំជំនួបពិភាក្សាការងារ និងសំដែងការគួរសមជាមួយឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ជំរុញការអនុវត្តតាមខ្លឹមសារដែលបានឯកភាពគ្នា រវាងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ជាមួយភាគីឡាវ ក្នុងឱកាសនៃដំណើរទស្សនកិច្ចផ្លូវការ កាលពីថ្ងៃទី២៧ខែមេសាឆ្នាំ២០១៥ ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

- បានសហការជាមួយអង្គការ UNODC ចុះត្រួតពិនិត្យនិងវាយតម្លៃលើកិច្ចប្រតិបត្តិការរបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ចំនួន ៩ បន្ថែមទៀត ពីថ្ងៃទី២៦ ខែមេសា ដល់ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ នៅការិយាល័យ BLO កំពង់ស្រឡៅ ខេត្តព្រះវិហារ, ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ, ដូង ខេត្តបាត់ដំបង, ព្រំ ខេត្តប៉ៃលិន, ចាំយាម ខេត្តកោះកុង, បាវិត ខេត្តស្វាយរៀង, ភ្នំដិន ខេត្តតាកែវ, ក្អមសំណ និង ជ្រៃធំ ខេត្តកណ្តាល
- ចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី នៃប្រទេសហត្ថលេខីលើអនុស្សរណៈនៃការយោគយល់គ្នាឆ្នាំ១៩៩៣ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ដែលរៀបចំនៅប្រទេសវៀតណាម កាលពីថ្ងៃទី២០-២៣ ខែឧសភា ឆ្នាំ២០១៥ ដែលដឹកនាំដោយ ឯ.ឧ អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (អគ្គលេខាធិការដ្ឋាន ៦ នាក់)
- ចូលរួមក្នុងក្រុមប្រតិភូក្រសួងមហាផ្ទៃកម្ពុជា ដើម្បីពិភាក្សាការងារជាមួយគណៈប្រតិភូជាន់ខ្ពស់នៃសាកលវិទ្យាល័យការពារជាតិ (NDC) នៃទីក្រុង NewDelhi ប្រទេសឥណ្ឌា (១៨/៥/២០១៥)
- ក្រសួងមហាផ្ទៃ បានចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយក្រសួងសន្តិសុខសាធារណៈនៃ

សាធារណៈរដ្ឋប្រជាមានិតចិន ស្តីពីកិច្ចសហប្រតិបត្តិការពាក់ព័ន្ធដល់ការបង្ក្រាបបទល្មើសដោយប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណែត

- សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីរៀបចំបែបបទបញ្ជូនមន្ត្រីទៅចូលរួមសិក្ខាសាលាស្តីពីការបន្តកិច្ចពិភាក្សាលើដំណើរការយន្តការ ACCORD នៅប្រទេសថៃ
- ទំនាក់ទំនងជាមួយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ដើម្បីរៀបចំបែបបទបញ្ជូនមន្ត្រីទៅចូលរួមសិក្ខាសាលាអាស៊ាន + ៣ ស្តីពីបណ្តាញឃ្លាំមើលគ្រឿងញៀនរបស់ ASEAN-NACO
- បន្តអនុវត្តគម្រោង ស្តីពីភាពជាដៃគូនៃមន្ត្រីអនុវត្តន៍ច្បាប់ក្នុងតំបន់ប្រឆាំងទៅនឹងឧក្រិដ្ឋកម្មឆ្លងដែន និងគ្រឿងញៀន (PATROL) ដំណាក់កាលទី២ ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- បាននិងកំពុងបន្តការរៀបចំផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បាននិងកំពុងរៀបចំសេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពរបស់គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- ចូលរួមកិច្ចប្រជុំឆ្លងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ កាលពីថ្ងៃ ទី២៨ ខែមេសា ឆ្នាំ២០១៥
- បាននឹងកំពុងបន្តការរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បាននិងកំពុងបន្តការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីសម្រាប់វិធីសាស្ត្រព្យាបាល ការគ្រប់គ្រង វិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន
- បាននិងកំពុងបន្តការរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពី ការបន្សាប និងការព្យាបាលទាំងផ្លូវកាយ និងផ្លូវចិត្តអ្នកញៀនគ្រឿងញៀន
- ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៤ និងទិសដៅការងារឆ្នាំ ២០១៥ របស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តកំពង់ចាម (២៥.៥.២០១៥) ។ អង្គសន្និបាត បានជំរុញការអនុវត្តផែនការ និងគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន និងការរៀបចំបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរហូតដល់ថ្នាក់ ស្រុក ក្រុង ឃុំ សង្កាត់
- ចូលរួមកិច្ចប្រជុំគណៈកម្មការទទួលអនុវត្តផែនការត្រួតពិនិត្យគ្រឿងញៀន របស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ នាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ ដែលមានសមាសភាពពាក់ព័ន្ធចូលរួមចំនួន ៤១ នាក់
- ថ្នាក់ដឹកនាំស្នងការដ្ឋាននគរបាលខេត្តពោធិ៍សាត់ បានចុះផ្សព្វផ្សាយអនុវត្តផែនការ និងគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ចំនួន ២ លើក នៅស្រុកភ្នំក្រវាញ និងស្រុកបាកាន មានមន្ត្រីនគរបាលថ្នាក់ស្រុក និងថ្នាក់ប៉ុស្តិ៍រដ្ឋបាលចូលរួមសរុប ៤១ នាក់
- ថ្នាក់ដឹកនាំស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម បានចុះដឹកនាំនិងត្រួតពិនិត្យលទ្ធផលការងាររបស់អធិការដ្ឋាននគរបាលស្រុកស្ទឹងត្រង់ មានមន្ត្រីចូលរួម ៤១ នាក់ ។

## IV. ផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀន ខែមិថុនា ឆ្នាំ២០១៥

១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

- ដឹកនាំប្រតិភូអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ទៅចូលរួមប្រារព្ធទិវាកុមារអន្តរជាតិលើកទី៦៦ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៥ នៅវិទ្យាល័យឥន្ទ្រទេវី
- សហការជាមួយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចុះផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្រុងសែនមនោរម្យ (០៩/៦/២០១៥) និង ស្រុកកែវសីម៉ា (១០/៦/២០១៥)
- រៀបចំ និងអញ្ជើញវាគ្មិនជាតំណាងមកពីក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដើម្បីផ្តល់កិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី ក្នុង ៖
  - កម្មវិធីព័ត៌មានពេលថ្ងៃ ក្រោមប្រធានបទស្តីពីការផ្សព្វផ្សាយអប់រំបង្ការបញ្ហាគ្រឿងញៀន ក្នុងវិស័យការងារ នៅកម្ពុជា (ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥)
  - កម្មវិធីសភាអ៊ីនធឺណែត ក្រោមប្រធានបទស្តីពីការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនក្នុងវិស័យអាកាសចរណ៍ នៅកម្ពុជា (ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥)
- រៀបចំទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥ នៅខេត្តសៀមរាប
- សហការជាមួយក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចុះផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅស្រុកសំពោងទង (ថ្ងៃទី២៧/៥/២០១៥) និង ក្រុងច្បារមន (២៩/៥/២០១៥)
- បន្តជំរុញក្រសួងអប់រំ យុវជន និងកីឡា រៀបចំសាលារៀនបៃតង (សាលារៀនគ្មានគ្រឿងញៀន)
- រៀបចំកម្មវិធីប្រឡងតែងកំណាព្យ និងគូរគំនូរប្រឆាំងគ្រឿងញៀន
- បន្តកិច្ចសហការជាមួយក្រសួងទេសចរណ៍ បោះពុម្ពស្ទីកឃ័រ (Sticker) ផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន ការជួញដូរកុមារ និងអាជីវកម្មផ្លូវភេទ និងរៀបចំផែនការសកម្មភាពផ្សព្វផ្សាយនិងបណ្តុះបណ្តាលក្រុមជនបង្គោល
- បន្តសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា ក្រសួងមហាផ្ទៃ រៀបចំវគ្គផ្សព្វផ្សាយចំណេះដឹងជាមូលដ្ឋានពីបញ្ហាគ្រឿងញៀន
- ជំរុញក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបណ្តុះបណ្តាលក្រុមជនបង្គោលនៅតាមរោងចក្រនិងសហគ្រាស
- បន្តកិច្ចសហការជាមួយក្រសួង ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្តគោលដៅ និងវិស័យឯកជន បញ្ជ្រាបការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈការប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុនឯកជននានា

២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

- ចូលរួមក្នុងសិក្ខាសាលាពិនិត្យលើផែនការយុទ្ធសាស្ត្រជាតិលើកទី៤ ឆ្លើយតបទូលំទូលាយនិងពហុវិស័យទៅនឹងមេរោគអេដស៍ ជំងឺអេដស៍ (ឆ្នាំ២០១៥-២០២០) តាមការអញ្ជើញរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥
- ជំរុញសកម្មភាពផ្សព្វផ្សាយឱ្យកាន់តែសកម្មថែមទៀត ដើម្បីឱ្យអ្នករងគ្រោះដោយសារគ្រឿងញៀនបាន

ដឹងនិងទៅទទួលយកសេវាព្យាបាលនៅតាមមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាពដែលនៅជិត

- ជំរុញក្រសួងសុខាភិបាល រៀបចំរបាយការណ៍ស្តីពីលទ្ធផលផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅកម្ពុជា សម្រាប់ធ្វើជាមូលដ្ឋានបន្តការកៀរគរថវិកាជំនួយ
- បន្តការកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- រៀបចំកិច្ចប្រជុំជាមួយតំណាងអយ្យការនិងតុលាការ ពិសេសនៅរាជធានីភ្នំពេញ ពាក់ព័ន្ធនឹងការចោទប្រកាន់អ្នកប្រើប្រាស់គ្រឿងញៀន ឱ្យទៅទទួលយកសេវាព្យាបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក
- ជំរុញក្រសួងសុខាភិបាល គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ដើម្បីពង្រឹងយន្តការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍
- សហការជាមួយក្រសួងសុខាភិបាល ធ្វើការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយថែមទៀតពីការអនុវត្តកម្មវិធីម្ទុល/ស៊ីរ៉ាំង នៅកម្ពុជា ។

៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

- បន្តរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីនៃកងយោធពលខេមរភូមិន្ទ នៅតាមតំបន់ប្រតិបត្តិការសឹករងខេត្តព្រះសីហនុ កោះកុង កែប និងខេត្តកំពត
- បន្តបើកវគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាពអនុវត្តន៍ច្បាប់តាមប្រព័ន្ធកុំព្យូទ័រ (CBT) តាមកម្មវិធីដូចខាងក្រោម ៖
  - ថ្ងៃទី២៥-២៩/៥/២០១៥ បណ្តុះបណ្តាលមន្ត្រីនគរបាលរាជធានីភ្នំពេញ ១២ នាក់ (វគ្គ៣/២០១៥)
  - ថ្ងៃទី៨-១២/៦/២០១៥ បណ្តុះបណ្តាលមន្ត្រីអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ១២ នាក់ (វគ្គ៤/ ២០១៥)
  - ថ្ងៃទី២២-២៦/៦/២០១៥ បណ្តុះបណ្តាលមន្ត្រីកងរាជអាវុធហត្ថ ១២ នាក់ (វគ្គ៥/២០១៥)
- បន្តបើកវគ្គបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន តាមប្រព័ន្ធអេឡិចត្រូនិច (e-Learning)
- រៀបចំកិច្ចប្រជុំ ពិភាក្សាក្នុងចំណោមស្ថាប័នពាក់ព័ន្ធការរៀបចំបង្កើតក្រុមការងារទប់ស្កាត់គ្រឿងញៀនតាមអាកាសយានដ្ឋានអន្តរជាតិ
- បន្តការពិនិត្យលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងសារធាតុថ្មីដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ រវាងកម្ពុជា-រុស្ស៊ី
- បន្តការពិនិត្យលើអនុសាសន៍នៃកិច្ចសហប្រតិបត្តិការជួយគ្នាទៅវិញទៅមក ស្តីពីវិធីសាស្ត្រនៃការប្រគល់ដោយមានការឃ្លាំមើល រវាងសហព័ន្ធសេវានៃរុស្ស៊ីក្នុងការត្រួតពិនិត្យការចរាចរគ្រឿងញៀន ជាមួយនឹងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- ត្រៀមរៀបចំពិធីប្រកាសសមាសភាព តួនាទី ភារកិច្ចរបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) នៅទូទាំងប្រទេស ។

៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

- រៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការគ្រប់គ្រង ត្រួតពិនិត្យការចរាចរ និងការប្រើប្រាស់សារធាតុគីមីផ្សំគ្រឿងញៀន នៅតាមរាជធានី ខេត្ត
- បន្តជំរុញក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្នុងការរៀបចំសេចក្តីព្រាងប្រកាសស្តីពីការដាក់ស្លាកសញ្ញា

សារធាតុគីមីក្នុងវិស័យឧស្សាហកម្ម

- សិក្សាស្រាវជ្រាវប្រមូលព័ត៌មានពាក់ព័ន្ធការប្រើប្រាស់សារធាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ដើម្បីដាក់បញ្ចូលទៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

- អនុវត្តតាមគោលការណ៍ដែលបានឯកភាពគ្នា ក្នុងដំណើរទស្សនកិច្ចនៅប្រទេសឡាវដែលដឹកនាំដោយឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ៖
  - ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា-ឡាវ លើកទី១ (ធ្វើនៅកម្ពុជា)
  - រៀបចំកិច្ចប្រជុំការិយាល័យទំនាក់ទំនងព្រំដែន កម្ពុជា-ឡាវ លើកទី១ (ធ្វើនៅកម្ពុជា)
- ត្រៀមចូលរួមកិច្ចប្រជុំការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-វៀតណាម លើកទី៣ ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងហូជីមិញ ប្រទេសវៀតណាម
- អនុវត្តកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការលើការងារអនុវត្តន៍ច្បាប់ និងការត្រួតពិនិត្យគ្រឿងញៀនដែលបានចុះហត្ថលេខាជាមួយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ។

៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

- សហការជាមួយអគ្គនាយកដ្ឋានកាំកុងត្រូល ដើម្បីជួបពិភាក្សាការងារជាមួយអ្នកសម្របសម្រួលថ្នាក់តំបន់អាស៊ី ប៉ាស៊ីហ្វិក ទទួលបន្ទុកកម្មវិធីត្រួតពិនិត្យគ្រឿងញៀនក្នុងកុងតឺន័រតាមសមុទ្រ របស់ការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្មនៃអង្គការ UNODC ដើម្បីសិក្សាស្វែងយល់ និងពិភាក្សាការងារជាមួយថ្នាក់ដឹកនាំកំពង់ផែស្វយ័តក្រុងព្រះសីហនុ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនក្នុងកុងតឺន័រនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ (២៦-២៧/៥/២០១៥)
- ចាត់បញ្ជូនមន្ត្រីទៅចូលរួមសិក្ខាសាលាពិភាក្សាលើដំណើរការយន្តការ ACCORD នៅប្រទេសថៃ នាថ្ងៃទី០៩-១០ ខែមិថុនា ឆ្នាំ ២០១៥
- សហការជាមួយមន្ត្រីសម្របសម្រួលថ្នាក់តំបន់អាស៊ី ប៉ាស៊ីហ្វិក ទទួលបន្ទុកកម្មវិធីត្រួតពិនិត្យគ្រឿងញៀនក្នុងកុងតឺន័រតាមសមុទ្រ របស់ការិយាល័យគ្រឿងញៀន
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនតាមយន្តការនៃបណ្តាប្រទេសក្នុងមហាអនុតំបន់ទន្លេមេគង្គ
- ចូលរួមសិក្ខាសាលាអាស៊ាន + ៣ ស្តីពីបណ្តាញឃ្លាំមើលគ្រឿងញៀន របស់ ASEAN-NACO ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២២-២៤ ខែមិថុនា ឆ្នាំ២០១៥ នៅទីក្រុងបាងកក ប្រទេសថៃ
- រៀបចំដំណើរទស្សនកិច្ចជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនអញ្ជើញទៅសាធារណរដ្ឋប្រជាមានិតចិន ។

៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- បន្តការរៀបចំផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- ចូលរួមកិច្ចប្រជុំពិភាក្សាលើកំណត់ហេតុនៃកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា ថៃ ដែលរៀបចំដោយក្រសួងមហាផ្ទៃ នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥
- បន្តការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ជំរុញការរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំង

គ្រឿងញៀន

- បន្តការរៀបចំសមាសភាព នៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- ជំរុញការរៀបចំសេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពលេខាធិការដ្ឋាន នៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរបស់ រាជធានី ខេត្ត
- រៀបចំកម្មវិធីផ្សព្វផ្សាយពីអនុសញ្ញាអន្តរជាតិស្តីពីគ្រឿងញៀន ដល់មន្ត្រីរាជការនៅតាមក្រសួង ស្ថាប័នដែលជាសមាជិករបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- រៀបចំកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់មេឃុំ ចៅសង្កាត់ នគរបាលប៉ុស្តិ៍រដ្ឋបាល និងមន្ត្រីអនុវត្តន៍ច្បាប់នានា នៅតាមរាជធានី ខេត្ត ។

អគ្គលេខាធិការ

ឧត្តមសេនីយ៍ឯក មាស_វីរិទ្ធ

**ចម្លងជូន**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.៣
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.៣

" ដើម្បីជូនជ្រាប "

- ក្រសួង ស្ថាប័ន សមាជិក អ.ជ.ប.គ.៣
- ក្រសួងផែនការ
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីមុខការ "

- ឯកសារ